ក្រុមប្រឹក្សាធម្មនុញ្ញ

# សេចក្តីថ្លែងការណ៍
# របស់
# អ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញបដិសេធយ៉ាងដាច់ខាតចំពោះការលើកឡើងរបស់ លោក ប្រ៊ែដ អាដាម នាយកប្រតិបត្តិទទួលបន្ទុកកិច្ចការតំបន់អាស៊ីរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ (Human Rights Watch) ដែលបានផ្សាយកាលពីថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៧ តាមវិទ្យុអាស៊ីសេរី ដែលធ្វើឲ្យប៉ះពាល់មកលើស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ និង ស្ថាប័នកំពូលៗដទៃទៀតរបស់ព្រះរាជាណាចក្រកម្ពុជា។

ការលើកឡើងរបស់លោក ប្រ៊ែដ អាដាម នេះ ជាការរំលោភលើឯករាជ្យ អធិបតេយ្យ រំលោភលើរដ្ឋធម្មនុញ្ញ និងកិច្ចការផ្ទៃក្នុងរបស់ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាធម្មនុញ្ញសូមថ្កោលទោស និង បដិសេធយ៉ាងដាច់អហង្ការចំពោះការមួលបង្កាច់ដោយចេតនាទុច្ចរិតរបស់បុគ្គលនេះ ដែលបានរំលោភបំពានធ្ងន់ធ្ងរដល់ស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ និងធ្វើឲ្យមានការភាន់ច្រឡំដល់សាធារណមតិជាតិ និង អន្តរជាតិ។៚

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧